**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 09-Sep-2019, 14:20
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**:

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ **សាធារណៈ:/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**ការឆ្លើយតបរបស់លោក ខៀវ សំផន ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងសេចក្តីជូនដំណឹងអំពីសាលដីកា ទៅដំណាក់កាលបណ្តឹងសាទុក្ខ (ឯកសារ F46/2/4)**

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្តីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE-MUMBA

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Cécile ROUBEIX
កញ្ញា Dounia HATTABI
លោក Stéphane NICOLAÏ

ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS (សហព្រះរាជអាជ្ញាបម្រុង)
លោក William SMITH (សហព្រះរាជអាជ្ញារង)

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ មេធាវីការពារក្តី នួន ជា ដែលបានប្តឹងសាទុក្ខប្រឆាំងនឹងការផ្តន្ទាទោសរូបគាត់ ក្នុងសំណុំរឿង ០០២/០២ មុនពេលគាត់ទទួលមរណភាព នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ បានដាក់សំណើមួយទាក់ទងនឹងផលប៉ះពាល់លើនីតិវិធីបណ្តឹងសាទុក្ខនៃការទទួលមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា[1]។

២. នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ តុលាការកំពូលបានសម្រេចរំលត់បណ្តឹងអាជ្ញាប្រឆាំងនឹង នួន ជា ហើយបានប្រកាសថាខ្លួននៅទទួលពិនិត្យសំណើរបស់មេធាវីការពារក្តីរបស់ នួន ជា[2]។

៣. នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ជាថ្ងៃចុងក្រោយនៃកាលកំណត់ដាក់ចម្លើយតប[3] សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("ដើមបណ្តឹងរដ្ឋប្បវេណី") បានឆ្លើយតបថាសាលក្រមសាលាដំបូងនៅតែមានសុពលភាព បើទោះបីជាមិនទាន់ចូលជាស្ថាពរ សម្រាប់រូប នួន ជា និងពុំមានអានុភាពតាមផ្លូវច្បាប់លើរូបគាត់យ៉ាងណាក្តី ដោយយោងតាមគោលការណ៍សច្ចធារណ៍និរទោស និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី[4]។

---

[1] សំណើបន្ទាន់ ទាក់ទងនឹងផលប៉ះពាល់លើនីតិវិធីបណ្តឹងសាទុក្ខនៃការទទួលមរណៈភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ ឯកសារ **F46/2** ជូនដំណឹងឯកសារភាសាអង់គ្លេស នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ និងភាសាខ្មែរ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩។

[2] សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ **F46/3** ("សេចក្តីសម្រេច **F46/3**")។

[3] យោងតាមមាត្រា ៨.៣ និង មាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្ត") ភាគីមានពេលវេលា ១០ ថ្ងៃ ដើម្បីឆ្លើយតប គិតចាប់ពីពេលជូនដំណឹងអំពីសំណើជាភាសាខ្មែរ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ពោលគឺរហូតដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។

[4] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសំណើបន្ទាន់របស់ នួន ជា ទាក់ទងនឹងផលប៉ះពាល់លើនីតិវិធីបណ្តឹងសាទុក្ខនៃការទទួលមរណៈភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ឯកសារ **F46/2/1** ("ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី")។

៤. នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ពោលគឺ ៣ ថ្ងៃ ក្រោយពីផុតកាលកំណត់ឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា សច្ចធារណ៍និរទោសពុំលាតសន្ធឹងដល់ដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៅ អ.វ.ត.ក ឡើយ ហើយទោះបីយ៉ាងណាក៏ដោយ ការប្រកាសពិរុទ្ធភាពរបស់ នួន ជា មិនគួរត្រូវទុកជាមោឃៈនោះទេ[5]។

៥. តាមរយៈសារណានេះ ដែលមេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") គិតថាខ្លួនមិនត្រូវធ្វើផងនោះ មេធាវីការពារក្តីសូមឆ្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញា ដោយសារតែសហព្រះរាជអាជ្ញាប្រកាន់ជំហរគួរឲ្យភ្ញាក់ផ្អើល ទាក់ទងនឹងសច្ចធារណ៍និរទោស នៅដំណាក់កាលបណ្តឹងសាទុក្ខ។ ក្នុងនាមជាជនជាប់ចោទកំពុងប្តឹងសាទុក្ខ លោក ខៀវ សំផន ត្រូវបង្ខំចិត្តចូលរួមក្នុងការជជែកដេញដោលមួយនេះ ដែលមែនទែនទៅវាមិនគួរជាការពិភាក្សាដេញដោលអ្វីនោះទេ ព្រោះថាក្របខ័ណ្ឌច្បាប់ ច្បាស់លាស់មិនអាចប្រកែកបានរួចទៅហើយ។

៦. ច្បាប់កម្ពុជា និងច្បាប់ អ.វ.ត.ក គឺមានភាពច្បាស់លាស់ខ្លាំងណាស់ត្រង់ចំណុចថា សច្ចធារណ៍និរទោស ត្រូវបន្តអនុវត្តក្នុងពេលប្តឹងសាទុក្ខ (I)។ វាជាសញ្ញាមួយគួរឲ្យសោកស្តាយបង្ហាញពីភាពខ្វះសេចក្តីក្លាហាន ដោយសារតែខ្លាចប្រតិកម្មផ្សេងៗដែលខ្លួនគិតទុកជាមុន ពីសំណាក់សាធារណមតិអន្តរជាតិ ជំហរដ៏អាស្រូវរបស់សហព្រះរាជអាជ្ញាគឺមិនទំនង ព្រោះថាបើទោះបីជាជនជាប់ចោទពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏គេត្រូវបានសន្មតថានៅតែបន្តទទួលបានសិទ្ធិ "ជាមូលដ្ឋាន" នៅដំណាក់កាលបណ្តឹងសាទុក្ខដែរ (II)។ ជាចុងក្រោយ ផលប៉ះពាល់នៃមរណភាពរបស់ជនជាប់ចោទដែលបានប្តឹងសាទុក្ខប្រឆាំងនឹងការផ្តន្ទាទោសលើរូបគេ មុនពេលចេញសាល

[5] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើបន្ទាន់ទាក់ទងនឹងផលប៉ះពាល់លើកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ នៃមរណភាពរបស់ នួន ជា មុនពេលចេញសាលដីកាបណ្តឹងសាទុក្ខ (F46/2) ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ឯកសារ **F46/2/4** ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា") ជូនដំណឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ជាភាសាអង់គ្លេស ហើយនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩ ជាភាសាខ្មែរ (និងភាសាបារាំង) នាំឲ្យកាលកំណត់នៃការឆ្លើយតបត្រូវចំថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩។ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ ពីរថ្ងៃក្រោយពីផុតកាលកំណត់នៃការឆ្លើយតប សហព្រះរាជអាជ្ញាបានស្នើសុំការអនុញ្ញាតដាក់ឯកសារជាភាសាអង់គ្លេសសិន ហើយមួយថ្ងៃក្រោយមក តុលាការកំពូលបានឯកភាពតាមសំណើនេះ ដោយទាំងតុលាការកំពូលពុំបានលើកឡើងពីភាពយឺតយ៉ាវនៃសំណើ និងការដាក់ចម្លើយតប (សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់សារណាតបមួយភាសា ទៅនឹងសំណើបន្ទាន់របស់ក្រុមមេធាវីការពារក្តី នួន ជា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ឯកសារ **F46/2/3**)។

ដីកា គឺពិតជាច្បាស់លាស់ខ្លាំងណាស់៖ ម្ចាស់បណ្តឹងសាទុក្ខស្លាប់ ត្រូវសន្មតថាគ្មានទោស ហើយ សាលក្រមដែលរងបណ្តឹងសាទុក្ខ ពុំមានតម្លៃជាសាលក្រមស្ថាពរនោះឡើយ (III)។

## I. ភាពច្បាស់លាស់នៃច្បាប់កម្ពុជា និងច្បាប់នៅ អ.វ.ត.ក.៖ សច្ចធារណ៍និរទោសត្រូវបន្តអនុវត្ត ក្នុងពេលប្តឹងសាទុក្ខ

៧. បើតាមសហព្រះរាជអាជ្ញា (ទាំងជាតិ និងអន្តរជាតិ) ការដែល អ.វ.ត.ក ត្រូវបានបង្កើតឡើងដើម្បី កាត់សេចក្តីអំពើសាហាវឃោរឃៅទ្រង់ទ្រាយធំ ទំនងជាមូលហេតុនាំឲ្យ អ.វ.ត.ក ត្រូវផ្តន្ទាទោស អំពើសាហាវឃោរឃៅទ្រង់ទ្រាយធំនេះ ដោយពុំគិតដល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង បទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស[6]។ ការពិត គឺផ្ទុយពីនេះ។

### ១. អ.វ.ត.ក ត្រូវបានបង្កើតឡើងដោយគោរពតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

៨. ចាប់ពីឆ្នាំ១៩៩៣ មក រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តត្រង់មាត្រា ៣៨ វាក្យខណ្ឌ ទី ៧ ថា៖

> "ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។

៩. នៅឆ្នាំ២០០៣ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា "ទាក់ទងនឹង ការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា" នូវចារីនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជា ប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") ត្រូវបានចុះហត្ថលេខា។ មាត្រា ១២ និងមាត្រា ១៣ នៃកិច្ច ព្រមព្រៀងចែងថា៖

---

[6] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១ កថាខណ្ឌ ៣-១៤។

"**មាត្រា ១២៖ នីតិវិធី**

១- នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា។ **នៅពេលណាដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ** ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

២- អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ។ (...)

**មាត្រា ១៣៖ សិទ្ធិរបស់ជនជាប់ចោទ**

១- សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរព**នៅទូទាំងដំណើរការនៃការជំនុំជម្រះក្ដី**។ សិទ្ធិបែបនេះជាពិសេស រួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថាគ្មានទោសពៃរ៍ហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង សិទ្ធិមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន សិទ្ធិទទួលបាននូវមេធាវី ប្រសិនបើជនជាប់ចោទ គ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និងសិទ្ធិពិនិត្យ ឬបានពិនិត្យសាក្សីដាក់បន្ទុក"។ (យើងខ្ញុំជាអ្នកដាក់អក្សរដិត)[7]។

១០. នៅឆ្នាំ២00៤ ច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្ដីពីការ

[7] សហព្រះរាជអាជ្ញាខកខានមិនបានបង្ហាញថា សិទ្ធិទាំងអស់នេះ ដែលក្នុងនោះមានសិទ្ធិទទួលបានសច្ចធារណ៍និរទោស ត្រូវបានគោរព "ពេញមួយរយៈពេលនៃដំណើរការនៃការជំនុំជម្រះ" នៅពេលខ្លួនយោងដោយផ្អែកទៅមាត្រា ១៣-១ នៃកិច្ចព្រមព្រៀង៖ ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣។

បង្កើត អ.វ.ត.ក") ត្រូវបានប្រកាសឲ្យប្រើដោយព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ដោយទ្រង់យល់ដំបូងគេនូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[8] ក្រោយពីក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាច្បាប់នេះស្របទៅនឹងរដ្ឋធម្មនុញ្ញ[9]។

១១. ច្បាប់នេះចែង ជាអាទិ៍ ថា អ.វ.ត.ក "ត្រូវរលាយខ្លួនជាស្វ័យប្រវត្តិ ក្រោយពេលដែលការវិនិច្ឆ័យទោសក្នុងរឿងក្តីនេះបានចប់*ជាស្ថាពរ*"[10] ហើយកិច្ចព្រមព្រៀងត្រូវអនុវត្តជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា[11] ដូចច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែរ។ លើសពីនេះទៀត ច្បាប់នេះចែងឡើងវិញពីបទប្បញ្ញត្តិនានានៃមាត្រា ១៣ នៃកិច្ចព្រមព្រៀង ដែលបានលើកឡើងពីខាងលើ[12] ដោយបានចែងយ៉ាងច្បាស់ ដូចគ្នាទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែរ៖។

> "ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"[13]។

១២. បើទោះជាកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានបង្កើតសាលាក្តីជាន់ខ្ពស់តែមួយថ្នាក់ (អង្គជំនុំជម្រះតុលាការកំពូល) ជំនួសឲ្យពីរថ្នាក់ ដូចមានចែងក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជា (សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ និងតុលាការកំពូល) ក៏ដោយ[14] ក៏ច្បាប់គ្រឹះទាំងពីរនេះ រួមទាំង

---

[8] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ទំព័រ ១៖ "**យើង ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី - បានទ្រង់យល់នូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា - បានទ្រង់យល់ (...) ប្រកាសឲ្យប្រើ (...)**"។

[9] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ទំព័រ ១។

[10] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៤៧ (យើងខ្ញុំជាអ្នកសរសេរជាអក្សរទ្រេត)។

[11] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៤៧ ស្ទួន, ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០ និងកំណត់សម្គាល់ជើងទំព័រលេខ ២៥។

[12] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣ វាក្យខណ្ឌទី ១ និង ២ និងមាត្រា ៣៧។

[13] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ និងមាត្រា ៣៧។ គួរកត់សម្គាល់ថា មាត្រា ៣៥ ពាក់ព័ន្ធ "តុលាការ" ជាទូទៅ ពុំមែនអង្គជំនុំជម្រះ ឬតុលាការកំពូលជាក់លាក់នោះទេ ដែលវាខុសគ្នាពីមាត្រា ៣៣ និង មាត្រា ៣៦។ ទោះយ៉ាងណាក៏ដោយ អនុលោមតាមមាត្រា ៣៧ "ប្រការដែលបានចែងនៅក្នុងមាត្រា ៣៣ ៣៤ និង ៣៥ ត្រូវអនុវត្តដូចគ្នាចំពោះការជំនុំជម្រះក្តីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល"។

[14] កិច្ចព្រមព្រៀង មាត្រា ៣, ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៩, ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦។

អ្នកតែងច្បាប់របស់ អ.វ.ត.ក បានបញ្ញត្តដូចគ្នានូវការគោរពសច្ចធារណ៍និរទោស រហូតដល់មានសាលក្រមស្ថាពរ ហើយច្បាប់ទាំងពីរនេះចែងដូចគ្នានឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

## ២. នៅកម្ពុជា និងនៅ អ.វ.ត.ក សិទ្ធិក្នុងការទទួលបានសច្ចធារណ៍និរទោស ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ត្រូវអនុវត្តយ៉ាងប្រាកដនៅក្នុងនីតិវិធីព្រហ្មទណ្ឌទាំងមូល

១៣. ក្រៅពីរដ្ឋធម្មនុញ្ញ កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក "ដែលមានគោលបំណងធ្វើការចងក្រងនូវនីតិវិធីជាធរមានរបស់កម្ពុជា សម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"[15] ទទួលស្គាល់យ៉ាងច្បាស់ដូចគ្នាដែរថា សច្ចធារណ៍និទោសត្រូវអនុវត្តលើនីតិវិធីព្រហ្មទណ្ឌទាំងមូល។

១៤. សហព្រះរាជអាជ្ញាបានលើកឡើងថា ខ្លឹមសារនៃវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង គាំទ្រអំណះអំណាងរបស់ខ្លួនថាសច្ចធារណ៍និរទោសលែងមានអត្ថិភាព ក្រោយពេលពិរុទ្ធភាពត្រូវបានរកឃើញនៅដំណាក់កាលជំនុំជម្រះនៅសាលាដំបូង[16]។ ក៏ប៉ុន្តែ អនុលោមតាមវិធាននេះ៖

> "ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប"។

១៥. ជាក់ច្បាស់ណាស់ វាពិតជាមានប្រយោជន៍ដែលត្រូវរម្លឹកថា បុគ្គលម្នាក់ដែលប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមផ្តន្ទាទោសរូបគាត់ ត្រូវស្ថិតនៅជាជន "ត្រូវចោទប្រកាន់" ដរាបណាសាលក្រមនោះមិនទាន់ចូលជាស្ថាពរ។ បុគ្គលនោះនៅតែរងបណ្តឹងអាជ្ញា។ ដូចគ្នានេះដែរ ដូចដែលមនុស្សគ្រប់រូប

---

[15] វិធានផ្ទៃក្នុង "អាស្រ័យហេតុនេះ"។

[16] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣។ សូមមើលផងដែរ កថាខណ្ឌ ៣ និងកំណត់សម្គាល់ជើងទំព័រលេខ ៦។

បានដឹង សិទ្ធិនៅស្ងៀមមិនឆ្លើយតប និងមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង "ជាប់ទាក់ទងយ៉ាងជិតស្និទ្ធ" នឹងសច្ចធារណ៍និរទោស[17]។ សិទ្ធិនេះមានវត្តមានដូចគ្នា "នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី" ហើយដូច្នេះ វត្តមាននេះមានរហូតដល់សាលក្រមចូលជាស្ថាពរ[18]។

១៦. ខ្លឹមសារនៃបទប្បញ្ញត្តិផ្សេងៗទៀតនៃវិធានផ្ទៃក្នុង និងភាពស៊ីសង្វាក់គ្នានៃបទប្បញ្ញត្តិទាំងនោះនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានគាំទ្រដោយឥតប្រកែកបាននូវការពិតដែលថា ពិរុទ្ធភាពមិនទាន់រកឃើញដរាបណាមិនទាន់ត្រូវបានរកឃើញជាស្ថាពរ និងបិទផ្លូវតវ៉ា។ យោងតាមវិធាន ១០៤ "សេចក្តីសម្រេចនៃអង្គជំនុំជម្រះតុលាការកំពូល គឺជាសេចក្តីសម្រេចចុងក្រោយ និងមិនត្រូវបង្វិលឱ្យអង្គជំនុំជម្រះសាលាដំបូងវិញឡើយ" (១០៤-៣) "អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង" ហើយតុលាការកំពូលអាច "បើកការពិនិត្យលើភ័ស្តុតាង និងស្វែងរកភ័ស្តុតាងថ្មី"(១០៤-១)។ "អង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចតម្កល់ ឬទុកជាមោឃៈ ឬកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមួយផ្នែក ឬទាំងស្រុងបាន ដូចមានចែងក្នុងវិធាន ១១០" (១០៤-២)[19]។

---

[17] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី Saunders ទល់នឹងចក្រភពអង់គ្លេស (សំណើលេខ ១៩១៨៧/៩១) សាលដីកា ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ កថាខណ្ឌ ៦៨, តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី Heaney និង McGuinness ទល់នឹងប្រទេសអៀឡង់ (សំណើលេខ ៣៤៧២០/៩៧) សាលដីកា ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០០ (ចូលជាស្ថាពរនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០១) កថាខណ្ឌ ៤០។ សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Lubanga សំណុំរឿងលេខ ICC-01/04-01/06 OA 11 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូងទី១ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៨, មតិជំទាស់លើផ្នែកខ្លះរបស់ចៅក្រម Georghios M. Pikis កថាខណ្ឌ ១៤។

[18] សូមមើលផងដែរ មាត្រា ៣៥ វាក្យខណ្ឌទី ២(ឆ) និងមាត្រា ៣៧ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[19] សូមមើលផងដែរ មាត្រា ៤០៥ និង មាត្រា ៤០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងថា សាលាឧទ្ធរណ៍អាចបដិសេធសាលក្រម ហើយឱ្យជនជាប់ចោទរួចខ្លួន ក៏ដូចជាអាចបង្ហាញ និងសម្រេចលើអង្គសេចក្តី។ សូមមើលតទៅទៀត នៅវាក្យខណ្ឌទី ១ នៃមាត្រា ៤៣៩ ដែលចែងថា តុលាការកំពូលអាចបដិសេធបណ្តឹងសាទុក្ខទាំងស្រុង ឬមួយផ្នែក ហើយអាចបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ដែលគេតវ៉ាចោលទាំងស្រុង ឬមួយផ្នែក។

១៧. អនុលោមតាមវិធាន ១១១(៦) "ក្នុងករណីដែលបណ្តឹងសាទុក្ខត្រូវបានបដិសេធ នោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវចូលជាស្ថាពរ និងមិនអាចតវ៉ាបានទៀតឡើយ"[20]។

១៨. ដូច្នេះ គឺមានតែពេលក្រោយពី "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះបានចូលជាស្ថាពរ" (១១៣-២) ប៉ុណ្ណោះ ទើបសហព្រះរាជអាជ្ញាត្រូវធ្វើការអនុវត្តទោស (វិធាន ១១៣-២)[21] ហើយ "ជនជាប់ចោទ" ក្លាយជា "ពិរុទ្ធជន" (វិធាន ១១២-១)[22]។

១៩. អាស្រ័យហេតុនេះ គ្មានអ្វីប្រកែកបានទេថា បើយោងតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងវិធាន ២១(១)(ឃ) ពិរុទ្ធភាព "មិនត្រូវបានរកឃើញទេ" ដរាបណាវាមិនត្រូវបានបង្ហាញឲ្យឃើញជា**ស្ថាពរ**ដោយសាលក្រមស្ថាពរ ហើយថាសច្ចធារណ៍និរទោសត្រូវបន្តអនុវត្តរហូតដល់ពេលនោះ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

---

[20] សូមមើលផងដែរ មាត្រា ៤៣៩ ត្រង់វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា៖ "ប្រសិនបើបណ្តឹងសាទុក្ខត្រូវបានបដិសេធ នោះសេចក្តីសម្រេចដែលតវ៉ាមានអាជ្ញាអស់ជំនុំ"។

[21] បញ្ជាក់អះអាងលើការបកស្រាយវាក្យខណ្ឌចុងក្រោយ នៃវិធាន ១០៤ (ដែលបញ្ជាក់ថា បណ្តឹងសាទុក្ខភ្លាមៗមិនមានអានុភាពបង្អង់នីតិវិធីមុខអង្គជំនុំជម្រះសាលាដំបូងទេ) ដែលចែងថា ផ្ទុយមកវិញ បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមមានអានុភាពបង្អង់នីតិវិធី។ សូមមើលផងដែរ មាត្រា ៣៩៨ ("នៅក្នុងរយៈពេលប្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រមត្រូវបង្អង់សិន") និងមាត្រា ៤៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("នៅក្នុងរយៈពេលសម្រាប់ធ្វើបណ្តឹងសាទុក្ខនោះ ការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ត្រូវបង្អង់សិន។ បណ្តឹងសាទុក្ខមានអានុភាពព្យួរ។ ការអនុវត្តសេចក្តីសម្រេចដែលត្រូវតវ៉ានេះ ត្រូវតែបង្អង់ ក្នុងខណៈដែលតុលាការកំពូលមិនទាន់បានសម្រេច")។ សូមមើលតទៅទៀត មាត្រា ៤៩៧ (សេចក្តីសម្រេចស្ថាពរ)៖ ("អយ្យការធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសម្រេចរបស់តុលាការ បានក្លាយទៅជាស្ថាពរ"។

[22] អនុលោមតាមវិធានផ្ទៃក្នុង បុគ្គលរងការចោទប្រកាន់ ត្រូវបានហៅថាជា "ជនជាប់ចោទ" ក្នុងដំណាក់កាលជំនុំជម្រះនៅសាលាដំបូង (វិធាន ៧៩ ដល់ ១០២) ហើយការហៅនេះគឺដូចគ្នានៅក្នុងដំណាក់កាលប្តឹងសាទុក្ខ (វិធាន ១០៤ ដល់ ១១១)។ ដូចគ្នាទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែរ ការហៅថា "ជនជាប់ចោទ" នៅដំណាក់កាលជំនុំជម្រះនៅសាលាដំបូង សាលាឧទ្ធរណ៍ និងនៅតុលាការកំពូល ត្រូវប្រែមកហៅថាជា "ទណ្ឌិត" ក្រោយពេលដែល "សាលក្រម និងសាលដីកាដែលស្ថាពរ ហើយដែលមានអាជ្ញាអស់ជំនុំ" (មាត្រា ៤៤៣ វាក្យខណ្ឌទី ១ និង មាត្រា ៤៤៦ វាក្យខណ្ឌទី ២)។ ទាក់ទងនឹងចំណុចនេះ មេធាវីការពារក្តីកត់សម្គាល់ថា សហព្រះរាជអាជ្ញានៅបន្តកំណត់ ខៀវ សំផន ថាជា "ជនជាប់ចោទ" ចាប់តាំងពីដំណើរការនីតិវិធីប្តឹងសាទុក្ខ ជាពិសេស នៅលើទំព័រដំបូងនៃចម្លើយតបរបស់សហព្រះរាជអាជ្ញា។

២០. យុត្តិសាស្ត្ររបស់ អ.វ.ត.ក បានត្រឹមតែជួយអះអាងបញ្ជាក់បន្ថែមតែប៉ុណ្ណោះ បើទោះជាសហព្រះរាជអាជ្ញាបានយក ឬមិនបានយកមកសំអាងក៏ដោយ។ យុត្តិសាស្ត្រទាំងពីររបស់អង្គជំនុំជម្រះដែលសហព្រះរាជអាជ្ញាលើកឡើងថា វាស្របគ្នាទៅនឹងការបកស្រាយបែបរឹតត្បិត កេងចំណេញរបស់ខ្លួន លើវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង[23] គឺតាមការពិតទៅ ផ្ទុយគ្នាទាំងស្រុង។ នៅក្នុងយុត្តិសាស្ត្រទីមួយ[24] អង្គជំនុំជម្រះរម្លឹកថា សច្ចធារណ៍និរទោស "គឺជាធាតុផ្សំចាំបាច់មួយនៃសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ គោលការណ៍នេះមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវិធាន ២១(ឃ) នៃវិធានផ្ទៃក្នុង មាត្រា ១៤-២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៦-២ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស (...)"។ ក្នុងយុត្តិសាស្ត្រទីពីរ[25] អង្គជំនុំជម្រះមិនត្រឹមតែយោងទៅវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុងតែមួយប៉ុណ្ណោះទេ តែថែមទាំងយោងទៅលើមាត្រា ១៣ នៃកិច្ចព្រមព្រៀង មាត្រា ៣៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏ដូចជាមាត្រា ១៤-២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៦-២ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស[26]។

២១. ម្យ៉ាងវិញទៀត ដូចដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើង[27] តុលាការកំពូលធ្លាប់បានរម្លឹកថា "សាលក្រមលើអង្គសេចក្តីមិនមែនជាសេចក្តីសម្រេចស្ថាពរនោះទេ រហូតទាល់តែសេចក្តីសម្រេចនេះឆ្លងកាត់ដំណាក់កាលនៃការប្តឹងសាទុក្ខសិន"។ តុលាការកំពូលបានយោងទៅវិធាន ១០៤ វិធាន ១១០ វិធាន ១១១ និងវិធាន ១១៣ នៃវិធានផ្ទៃក្នុង មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ

---

[23] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤។

[24] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤ និងកំណត់សម្គាល់ជើងទំព័រលេខ ៣៧ (យោងទៅកថាខណ្ឌ ១៦ នៃសេចក្តីសម្រេច E176/2)។

[25] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤ និងកំណត់សម្គាល់ជើងទំព័រលេខ ៣៨ (យោងទៅកថាខណ្ឌ ៤៤ នៃសាលក្រមក្នុងសំណុំរឿង ឌុច)។

[26] សូមមើល កំណត់សម្គាល់ជើងទំព័រ ៦២ នៃកថាខណ្ឌ ៤៤ នៃសាលក្រមក្នុងសំណុំរឿង ឌុច ដែលសហព្រះរាជអាជ្ញាយោង។

[27] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦ និងកំណត់សម្គាល់ជើងទំព័រលេខ ១១ (យោងទៅកថាខណ្ឌ ២៤ នៃសេចក្តីសម្រេច E163/5/1/13)។

កម្ពុជា និងមាត្រាមួយចំនួននៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[28]។ បន្ថែមលើនេះ មេធាវីការពារក្ដីសូមរម្លឹកថា មានពេលមួយទៀតនោះ តុលាការកំពូលបានសម្រេចថា៖

> "អនុលោមតាមមាត្រា ១២-២ និងមាត្រា ១៣-១ នៃកិច្ចព្រមព្រៀង មាត្រា ៣៣ (ថ្មី) និងមាត្រា ៣៥ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែលយោងដោយផ្ទាល់លើមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិស្ដីពីគោលការណ៍សច្ចធារណ៍និរទោស អាចយកមកអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក"[29]។

២២. ដូច្នេះ វាពិតជាពិបាកទទួលយកបានខ្លាំងណាស់ដែលសហព្រះរាជអាជ្ញាបានសរសេរក្នុងចម្លើយតបរបស់ខ្លួនថា "មាត្រា ៣៥ និង ៣៧ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មិនស៊ីចង្វាក់គ្នាទៅនឹងនីតិវិធី និងការអនុវត្តដែលពាក់ព័ន្ធនៅក្នុងកម្រិតអន្តរជាតិទេ"[30] ខណៈដែលការពិត គឺផ្ទុយពីការលើកឡើងនេះទាំងស្រុង។

## ៣. <u>បទដ្ឋានកម្ពុជាជាធរមាននៅ អ.វ.ត.ក ស្ដីពីសច្ចធារណ៍និរទោស មានភាពស្របគ្នាល្អឥតខ្ចោះជាមួយបទដ្ឋានអន្តរជាតិ</u>

២៣. ដូចតុលាការកំពូល និងសាលាដំបូងបានលើកឡើងរួចមកហើយ បទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងបញ្ហានេះមាន ជាអាទិ៍ មាត្រា ១៤-២ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៦-២ នៃអនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិមនុស្ស ដែលចែងតាមរបៀបដូចគ្នាថា៖

---

[28] ជាពិសេស មាត្រា ៣៩៨ មាត្រា ៤០៥ មាត្រា ៤០៦ និងមាត្រា ៤៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ (កំណត់សម្គាល់ជើងទំព័រលេខ ៦៧ នៃសេចក្ដីសម្រេច E163/5/1/13)។

[29] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ **E176/2/1/4** កថាខណ្ឌ ៥២។ មេធាវីការពារក្ដីកត់សម្គាល់ថា បន្ទាប់មក តុលាការកំពូលបានពិនិត្យលើបញ្ហាជ្រៀតជ្រែករបស់រដ្ឋនៅក្នុងនីតិវិធីព្រហ្មទណ្ឌកំពុងដំណើរការ នៅក្នុងយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអន្តរជាតិនានា មុនគេទាំងអស់ ដោយហេតុតែពុំមានយុត្តិសាស្ត្រ ឬការអនុវត្តពាក់ព័ន្ធនៅក្នុងកម្រិតជាតិ។

[30] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤។

"ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់"[31]។

២៤. ទោះបីជាមាត្រាទាំងនេះមិនបញ្ជាក់ច្បាស់ថា ពិរុទ្ធភាពត្រូវបានកំណត់ស្របតាមច្បាប់ កាលបើត្រូវបានរកឃើញជាស្ថាពរ (ដូចក្នុងវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង) ក៏ដោយ ក៏នេះជាប្រត្យក្សភាពដោយសារតែអត្ថបទច្បាប់ទាំងពីរនេះចែងអំពីសិទ្ធិរបស់ "ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ" ក្នុងការ "សុំឱ្យសាលាក្តីជាន់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញស្របតាមច្បាប់"[32]។ អត្ថបទច្បាប់ទាំងពីរនេះចែងផងដែរថា "គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសាជាថ្មីឡើយ ចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ"[33]។

២៥. ប្រត្យក្សភាពនេះត្រូវបានរម្លឹកដោយយុត្តិសាស្ត្រ យ៉ាងច្បាស់លាស់បំផុត។ បើតាមតុលាការសិទ្ធិមនុស្សអឺរ៉ុប មាត្រា ៦-២ "គ្រប់គ្រងលើនីតិវិធីព្រហ្មទណ្ឌទាំងមូល"[34]។ "បើគ្មានការផ្តន្ទាទោសជាស្ថាពរ" ពិរុទ្ធភាពមិនត្រូវបាន "បង្ហាញស្របតាមច្បាប់"[35] ឡើយ។ តុលាការសិទ្ធិមនុស្សអឺរ៉ុបក៏

[31] ភាពខុសគ្នាតែមួយគត់រវាងអត្ថបទច្បាប់ទាំងពីរ គឺថា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ប្រើពាក្យ "បទព្រហ្មទណ្ឌ" ឯអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ប្រើត្រឹមតែពាក្យ "បទល្មើស"។

[32] មាត្រា ១៤-៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងមាត្រា ២-១ នៃពិធីសារលេខ ៤ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស។

[33] មាត្រា ១៤-៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងមាត្រា ៤-១ នៃពិធីសារលេខ ៤ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស។

[34] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី Minelli ទល់នឹងប្រទេសស្វ៊ីស (សំណើលេខ ៨៦៦០/៧៩) សាលដីកា ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៨៣ កថាខណ្ឌ ៣០, រឿងក្តី Matijašević ទល់នឹងប្រទេសស៊ែប៊ី (សំណើលេខ ២៣០៣៧/០៤) សាលដីកា ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦ (ចូលជាស្ថាពរ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦) ("សាលដីកា Matijašević ទល់នឹងប្រទេសស៊ែប៊ី") កថាខណ្ឌ ៤៦ និងកថាខណ្ឌ ៤៩, រឿងក្តី Nešťák ទល់នឹងប្រទេសស្លូវ៉ាគី (សំណើលេខ ៦៥៥៥៩/០១) សាលដីកា ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧ (ចូលជាស្ថាពរ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៧) ("សាលដីកា Nešťák ទល់នឹងប្រទេសស្លូវ៉ាគី") កថាខណ្ឌ ៨៨, រឿងក្តី Poncelet ទល់នឹងប្រទេសប៊ែលហ្ស៊ិក (សំណើលេខ ៤៤៤១៨/០៧) សាលដីកា ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ (ចូលជាស្ថាពរ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១០) កថាខណ្ឌ ៤៩-៥០។

[35] សាលដីកា Matijašević ទល់នឹងប្រទេសស៊ែប៊ី កថាខណ្ឌ ៤៨-៤៩ សាលដីកា Nešťák ទល់នឹងប្រទេសស្លូវ៉ាគី កថាខណ្ឌ

ធ្លាប់បានរម្លឹកផងដែរថា គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុបបានទទួលស្គាល់មុនខ្លួនថា “សច្ចធារណ៍និរទេសលែងអនុវត្តតែតាមរយៈការផ្ដន្ទាទោសសាមីខ្លួនជាស្ថាពរតាមផ្លូវច្បាប់ប៉ុណ្ណោះ”[36] មុននឹងប្រកាសថា៖

> “តុលាការយល់ឃើញថាមានប្រយោជន៍ក្នុងការរម្លឹកផងដែរថា អនុសញ្ញាត្រូវបកស្រាយក្នុងន័យធានាសិទ្ធិជាក់ស្ដែង និងមានប្រសិទ្ធភាព គឺមិនមែនត្រឹមតែជាទ្រឹស្ដី ឬជាការបំភាន់ទេ។ ដូច្នេះ យោងតាមការរៀបរាប់ខាងលើ តុលាការយល់ឃើញថា **សច្ចធារណ៍និរទោសនឹងលែងអនុវត្តនៅដំណាក់កាលបណ្ដឹងសាទុក្ខ ដោយសារតែនីតិវិធីនៅសាលាដំបូងបានបណ្ដាលឱ្យមានការផ្ដន្ទាទោសសាមីខ្លួនប៉ុណ្ណោះ។ សេចក្ដីសន្និដ្ឋានបែបនេះមានលក្ខណៈផ្ទុយនឹងតួនាទីរបស់នីតិវិធីបណ្ដឹងសាទុក្ខ** ដែលក្នុងពេលនោះ ចៅក្រមមានសមត្ថកិច្ចត្រូវវិនិច្ឆ័យឡើងវិញនូវសេចក្ដីសម្រេចដែលប្រគល់ជូនខ្លួន ទាំងលើអង្គហេតុ និងអង្គច្បាប់។ ហេតុនេះ សច្ចធារណ៍និរទោសនឹងមិនអាចអនុវត្តបានទេនៅក្នុងនីតិវិធី ដែលតាមរយៈនោះសាមីខ្លួនស្នើសុំឱ្យមានការជំនុំជម្រះសាជាថ្មីលើរឿងក្ដីរបស់ខ្លួន និងលុបចោលការផ្ដន្ទាទោសពីមុន”[37] (យើងខ្ញុំជាអ្នកដាក់អក្សរដិត)។

២៦. ដោយសារតែនីតិវិធីបណ្ដឹងសាទុក្ខមានតួនាទីកែប្រែកំហុស សូម្បីតែជនជាប់ចោទពីបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរបំផុត ដែលមានសិទ្ធិប្ដឹងសាទុក្ខ ក៏នៅតែបន្តទទួលបានសិទ្ធិជាមូលដ្ឋាន និយាយជារួម និងសច្ចធារណ៍និរទោស និយាយដោយឡែក ក្រោយពីការផ្ដន្ទាទោសនៅសាលាដំបូង រហូតដល់ពេលសាលក្រមចូលជាស្ថាពរ។

---

៨៩, រឿងក្ដី Ismoilov និងអ្នកឯទៀត ទល់នឹងប្រទេសរុស្ស៊ី (សំណើលេខ ២៩៤៧/០៦) សាលដីកា ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ (ចូលជាស្ថាពរ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨) កថាខណ្ឌ ១៦៦។

[36] រឿងក្ដី Konstas ទល់នឹងប្រទេសក្រិក (សំណើលេខ ៥៣៤៦៦/០៧) សាលដីកា ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ (ចូលជាស្ថាពរ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១) (សាលដីកា Konstas ទល់នឹងប្រទេសក្រិក) កថាខណ្ឌ ៣៥ (ដកឃោងចេញ)។

[37] សាលដីកា Konstas ទល់នឹងប្រទេសក្រិក កថាខណ្ឌ ៣៦ (ដកឃោងចេញ)។

## II. ភាពមិនសមហេតុផលនៃគោលជំហរគួរឲ្យអាម៉ាស់ និងខ្វះសេចក្តីក្លាហានរបស់សហព្រះរាជអាជ្ញា៖ សូម្បីតែជនជាប់ចោទពីបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរបំផុតក៏ត្រូវបានសន្មតថានៅតែបន្តទទួលបានសិទ្ធិ "ជាមូលដ្ឋាន" នៅដំណាក់កាលបណ្តឹងសាទុក្ខ

២៧. សហព្រះរាជអាជ្ញាស្នើឲ្យតុលាការកំពូលអង្គុយលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា យុត្តិសាស្ត្ររបស់ខ្លួន បទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងខ្លឹមសារគោលនៃសិទ្ធិធ្វើបណ្តឹងសាទុក្ខតែម្តង ដើម្បីអាចគោរពតាម "ការអនុវត្តដែលត្រូវបានអនុម័តយកដោយតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀត" ដោយសារតែ "អាណត្តិ រចនាសម្ព័ន្ធ និងគោលដៅស្រដៀងគ្នា" នឹង អ.វ.ត.ក[38]។ ដោយហេតុថា អ.វ.ត.ក និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ កាត់សេចក្តីឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ហើយពិនិត្យលើបណ្តឹងសាទុក្ខតែមួយថ្នាក់ និងមានលក្ខណៈវិនិច្ឆ័យមួយចំនួននៃការពិនិត្យលើបណ្តឹងសាទុក្ខ[39] អ.វ.ត.ក គួរតែអនុវត្តតាម "វិធីសាស្ត្រ"[40] ដូចមានក្នុងសេចក្តីសម្រេចតែមួយគត់របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលត្រូវបានដកស្រង់ដោយសង្ខេប នៅក្នុងសេចក្តីសម្រេចផ្សេងទៀតតែមួយគត់របស់តុលាការនេះ[41]។

២៨. ក៏ប៉ុន្តែ ការអនុវត្តតាមសេចក្តីសម្រេចអយុត្តិធម៌ និងអញ្ញទិដ្ឋិកនេះ មិនត្រឹមតែផ្ទុយនឹងច្បាប់ជាធរមាននៅ អ.វ.ត.ក ប៉ុណ្ណោះទេ ថែមទាំងផ្ទុយនឹងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដែល តាមពិត ក៏ទទួលស្គាល់សិទ្ធិក្នុងការទទួលបានសច្ចធារណ៍និរទោស នៅដំណាក់កាលបណ្តឹងសាទុក្ខផងដែរ។ ជាក់ស្តែង ជនជាប់ចោទអាចត្រូវបានដោះលែង នៅដំណាក់កាលបណ្តឹងសាទុក្ខ បើទោះជា អ.វ.ត.ក និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិមានយុត្តាធិការតែមួយថ្នាក់លើបណ្តឹងសាទុក្ខ និងមានលក្ខណៈវិនិច្ឆ័យមួយចំនួននៃការពិនិត្យលើបណ្តឹងសាទុក្ខក៏ដោយ ។

---

[38] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧ និងកថាខណ្ឌ ៩។

[39] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១ កថាខណ្ឌ ៦ និងកថាខណ្ឌ ៧។

[40] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០។

[41] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨-៩។

**១. <u>សូម្បីតែជនជាប់ចោទនៅ អ.វ.ត.ក និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ក៏អាចត្រូវបានដោះលែងនៅដំណាក់កាលបណ្តឹងសាទុក្ខដែរ</u>**

២៩. ទោះបីជាជនជាប់ចោទនៅ អ.វ.ត.ក និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មានតែយុត្តាធិការចាត់ការលើបណ្តឹងសាទុក្ខតែមួយថ្នាក់ក៏ដោយ ក៏សាលាក្តីជាន់ខ្ពស់ពិនិត្យមើលឡើងវិញនូវសាលក្រមរបស់សាលាដំបូង ទាំងលើអង្គហេតុ និងអង្គច្បាប់[42]។ ទោះបីជាសាលាក្តីជាន់ខ្ពស់យល់ឃើញថាខ្លួនត្រូវគោរពការរកឃើញខាងអង្គហេតុរបស់សាលាដំបូងក៏ដោយ[43] ក៏គំនិតនេះត្រូវយល់ "ដោយប្រុងប្រយ័ត្នខ្ពស់" ដោយសារតែតុលាការជាន់ខ្ពស់អាចបដិសេធការរកឃើញទាំងនេះ "រៀងរាល់ពេលដែលការមិនធ្វើអន្តរាគមន៍អាចបណ្តាលឲ្យមានកំហុសនាំឲ្យមានការភាន់ច្រឡំ ក្នុងការសម្រេចសេចក្តីរបស់តុលាការ"[44]។

៣០. ទោះជាយ៉ាងណាក៏ដោយ ការពិនិត្យមើលឡើងវិញនូវសាលក្រមសាលាដំបូងលើអង្គហេតុ និងអង្គច្បាប់ ដោយតុលាការជាន់ខ្ពស់តែមួយថ្នាក់ អាចនាំឲ្យមានការកែប្រែសាលក្រមនេះទាំងស្រុង ឬមួយផ្នែក។ ហេតុនេះហើយបានជាជនជាប់ចោទនៅ អ.វ.ត.ក នៅតែបន្តទទួលបានសិទ្ធិទាំងស្រុងដែលត្រូវបានទទួលស្គាល់ រហូតដល់ពេលសាលក្រមចូលជាស្ថាពរ[45] ដូចជាសិទ្ធិទទួលបានសច្ចធារណ៍និរទោស ដែលលាតសន្ធឹងហួសនេះទៅទៀត ក្នុងករណីដោះលែងជាស្ថាពរ[46]។

---

[42] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦។ មេធាវីការពារក្តីកត់សម្គាល់ថា ទោះបីជាតុលាការកំពូលបានអនុវត្តតាមលក្ខណៈវិនិច្ឆ័យនៃការពិនិត្យលើបណ្តឹងសាទុក្ខរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិក៏ដោយ (ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥) ក៏តុលាការកំពូលធ្វើយ៉ាងណាឲ្យធានាបានថា នីតិវិធី "អនុវត្តតាមលក្ខណៈពិសេសនៃការពិនិត្យឡើងវិញនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍" របស់កម្ពុជា ហើយមូលដ្ឋានបណ្តឹងសាទុក្ខ "ក៏រួមបញ្ចូលទាំងមូលហេតុនៃបណ្តឹងសាទុក្ខទៅតុលាការកំពូលកម្ពុជា"៖ សាលដីកា ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ សំណុំរឿង ០០១ ឯកសារ **F28** ("សាលដីកា ឌុច") កថាខណ្ឌ ១៣។

[43] ចម្លើយរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦ និងកំណត់សម្គាល់ជើងទំព័រលេខ ១៥។

[44] រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Bemba សំណុំរឿងលេខ ICC-01/05-01/08 A សាលដីកាលើបណ្តឹងសាទុក្ខរបស់ Jean-Pierre Bemba Gombo ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទី ៣ ដែលបានចេញអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ ("សាលដីកា Bemba") កថាខណ្ឌ ៣៨-៤០។

[45] ឧទាហរណ៍ សូមមើលមាត្រា ១២-២ និង ១៣-១ នៃកិច្ចព្រមព្រៀង ព្រមទាំងមាត្រា ៣៣ មាត្រា ៣៥ និងមាត្រា ៣៧ នៃ

៣១. ដូចសហព្រះរាជអាជ្ញាដឹងស្រាប់ហើយ តួនាទីកែប្រែកំហុសរបស់នីតិវិធីបណ្តឹងសាទុក្ខបាននាំទៅដល់ការដោះលែងជនជាប់ចោទ នៅដំណាក់កាលបណ្តឹងសាទុក្ខ នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ដូចជា តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ជាដើម) ដែលត្រូវបានសាលាដំបូងប្រកាសថាមានពិរុទ្ធ និងផ្តន្ទាទោស[47]។

៣២. ដូចសហព្រះរាជអាជ្ញាដឹងរឹតតែច្បាស់ទៅទៀត ពីព្រោះខ្លួនមានវត្តមាននៅក្នុងសំណុំរឿង ០០២/០១ ហើយតុលាការកំពូលបានរម្លឹក នៅថ្ងៃទី១៣ ខែសីហា កន្លងទៅនេះ នៅក្នុងសេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ នួន ជា[48] តុលាការកំពូលបានបដិសេធពិរុទ្ធភាពមួយចំនួនរបស់ ខៀវ សំផន និង នួន ជា ដែលសាលាដំបូងបានប្រកាស[49]។ តុលាការកំពូលបានសម្រេចថា

---

ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[46] បើតាមតុលាការសិទ្ធិមនុស្សអឺរ៉ុប ការសម្តែងមន្ទិលសង្ស័យលើភាពគ្មានទោសរបស់ជនជាប់ចោទ ក្រោយការដោះលែងចូលជាស្ថាពរ មិនស្របគ្នានឹងសច្ចធារណ៍និរទោសទេ៖ រឿងក្តី Sekanina ទល់នឹងប្រទេសអូទ្រីស (សំណើលេខ ១៣១២៦/៨៧) សាលដីកា ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៣៖ កថាខណ្ឌ ៣០, រឿងក្តី Rushiti ទល់នឹងប្រទេសអូទ្រីស (សំណើលេខ ២៨៣៨៩/៩៥) សាលដីកា ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០០ (ចូលជាស្ថាពរ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០) កថាខណ្ឌ ៣១, រឿងក្តី O. ទល់នឹងប្រទេសន័រវេស (សំណើលេខ ២៩៣២៧/៩៥) សាលដីកា ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ (ចូលជាស្ថាពរ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៣) កថាខណ្ឌ ៣៩, រឿងក្តី Geerings ទល់នឹងប្រទេសហូល្លង់ (សំណើលេខ ៣០៨១០/០៣) សាលដីកា ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៧ (ចូលជាស្ថាពរ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៧) កថាខណ្ឌ ៤៩-៥០, រឿងក្តី Vassilios Stavropoulos ទល់នឹងប្រទេសក្រិក (សំណើលេខ ៣៥៥២២/០៤) សាលដីកា ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ (ចូលជាស្ថាពរ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧) ("សាលដីកា Vassilios Stavropoulos ទល់នឹងប្រទេសក្រិក") កថាខណ្ឌ ៣៨, រឿងក្តី Paraponiaris ទល់នឹងប្រទេសក្រិក (សំណើលេខ ៤២១៣២/០៦) សាលដីកា ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ (ចូលជាស្ថាពរ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩) កថាខណ្ឌ ៣២។

[47] ឧទាហរណ៍៖ ១) នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី៖ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Orić សំណុំរឿងលេខ IT-03-68-A សាលដីកា ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៨, ២) នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា៖ រឿងក្តី Zigiranyirazo ទល់នឹងរដ្ឋអាជ្ញា សំណុំរឿងលេខ ICTR-01-73-A សាលដីកា ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩, ៣) នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ សាលដីកា Bemba។

[48] សេចក្តីសម្រេច **F46/3** កថាខណ្ឌ ២។

[49] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** ("សាលដីកាសំណុំរឿង ០០២/០១")។

សាលាដំបូងបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើន និងបានសន្និដ្ឋានថាវិធីសាស្ត្រពិនិត្យភ័ស្តុតាងរបស់សាលាដំបូងជារឿយៗ មានភាពមិនសមហេតុផល[50]។

៣៣. សាលាដំបូងដដែលនេះបានចេញសាលក្រមលើសំណុំរឿង ០០២/០២ ព្រមទាំងបានប្រកាសថា ខៀវ សំផន និង នួន ជា មានពិរុទ្ធពីបទសម្លាប់រង្គាលនៅភ្នំក្រោល ខណៈដែលខ្លួនបានរកឃើញថា ឧក្រិដ្ឋកម្មនេះមិនបានកើតឡើងនៅទីនោះទេ...[51]។ ការគោរពតាមគោលជំហររបស់សហព្រះរាជអាជ្ញាមានន័យស្មើនឹងយល់ឃើញថា លោក នួន ជា ទទួលមរណភាព ដោយនាំយកទៅជាមួយនូវពិរុទ្ធភាពពីបទឧក្រិដ្ឋមួយដែលមិនត្រូវបានរកឃើញថាបានកើតឡើង ហើយលោក ខៀវ សំផន លែងត្រូវបានសន្មតជាមុនថាជាជនគ្មានទោសទៀតហើយ ខណៈដែលការប្រកាសពិរុទ្ធភាពត្រូវតែបដិសេធចោលជាដាច់ខាត នៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ។

៣៤. ដូច្នេះ ទោះបីជាសហព្រះរាជអាជ្ញានិយាយយ៉ាងណាក៏ដោយ[52] លក្ខណៈវិនិច្ឆ័យនៃការពិនិត្យលើបណ្តឹងសាទុក្ខដែលអនុវត្តដោយតុលាការជាន់ខ្ពស់តែមួយថ្នាក់ នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងនៅ អ.វ.ត.ក មិនអាចជាមូលហេតុនាំឲ្យទៅដល់ការលែងអនុវត្តសច្ចធារណ៍និរទោស នៅដំណាក់កាលបណ្តឹងសាទុក្ខបានឡើយ ពីព្រោះច្បាស់ណាស់ថា វិមតិសង្ស័យនៅតែបន្តបានជាប្រយោជន៍ដល់ជនជាប់ចោទ ក្នុងដំណាក់កាលបណ្តឹងសាទុក្ខ នៅចំពោះមុខយុត្តាធិការទាំងនេះ។

## ២. <u>សូម្បីតែជនជាប់ចោទ នៅ អ.វ.ត.ក និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មានសិទ្ធិទទួលបានវិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ នៅដំណាក់កាលបណ្តឹងសាទុក្ខ</u>

[50] ចំពោះឧទាហរណ៍ខ្លះៗ សូមមើលកថាខណ្ឌ ៤៥៤ កថាខណ្ឌ ៦៣១ (“យោងតាមភ័ស្តុតាងដែលមានមូលដ្ឋានខ្សោយបែបនេះ ពុំមានតុលាការអង្គហេតុសមស្របណាមួយអាចផ្តល់ការយល់ឃើញបែបនេះបានឡើយ”) កថាខណ្ឌ ៦៣៣ កថាខណ្ឌ ៦៣៧ កថាខណ្ឌ ៩៧០ នៃសាលដីកាសំណុំរឿង ០០២/០១។

[51] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កំហុស ១៨.២៧៩ និង ១៩.១, សេចក្តីជូនដំណឹងរបស់ នួន ជា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/3/1** មូលដ្ឋានទី ២៥១។

[52] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦-៨។

៣៥. បើយើងខំគិតតែបន្តិចថាតើអ្វីជាសច្ចធារណ៍និរទោសនោះ យើងពិតជាមិនអាចគាំទ្រដល់ទស្សនៈរបស់សហព្រះរាជអាជ្ញា ដែលផ្អែកលើសេចក្តីសម្រេចតែមួយគត់របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានឡើយ។

៣៦. គោលការណ៍សច្ចធារណ៍និរទោស "តម្រូវថា ក្នុងពេលបំពេញមុខងារ សមាជិកតុលាការមិនត្រូវមានបុរេវិនិច្ឆ័យថាជនជាប់ចោទបានប្រព្រឹត្តអំពើដែលចោទប្រកាន់នោះទេ ហើយតម្រូវទៀតថា បន្ទុកបង្ហាញភ័ស្តុតាងមានទម្ងន់លើបទចោទ និងវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"[53]។

៣៧. ក៏ប៉ុន្តែ សូម្បីតែនៅចំពោះមុខ អ.វ.ត.ក និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ បន្ទុកបង្ហាញភ័ស្តុតាងមិនអាចត្រូវបានច្រានចោលទេ ហើយវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។ ជាក់ស្តែង ដោយផ្អែកលើយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ តុលាការកំពូលបានប្រកាសយ៉ាងច្បាស់ និងត្រឹមត្រូវថា៖

> "ដោយពិចារណាឃើញថា ពិរុទ្ធភាពរបស់ជនជាប់ចោទត្រូវតែបង្ហាញថាគ្មានវិមតិសង្ស័យក្នុងដំណាក់កាលជំនុំជម្រះ ទើបអង្គជំនុំជម្រះតុលាការកំពូលត្រូវវាយតម្លៃចំណុចសំខាន់ៗនៃកំហុសអង្គហេតុដែលបណ្តាលឲ្យមានភាពមិនយុត្តិធម៌ ទៅលើចំណុចដែលម្ចាស់បណ្តឹងសាទុក្ខចង់បង្ហាញ។ ដូច្នេះហើយ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចឲ្យរួចខ្លួន មានភាពខុសគ្នាពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីប្រឆាំងនឹងការសម្រេចដាក់ពិរុទ្ធភាព។ បណ្តឹងសាទុក្ខប្រឆាំងនឹងការសម្រេចដាក់ពិរុទ្ធភាពត្រូវបង្ហាញថា កំហុសអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងមានវិមតិសង្ស័យ ចំពោះការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ។ ក្នុងករណីដែលមានការលើកឡើងថា អង្គជំនុំជម្រះសាលា

---

[53] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី Barberà, Messegué និង Jabardo ទល់នឹងប្រទេសអេស្ប៉ាញ (សំណើលេខ ១០៥៩០/៨៣) សាលដីកា ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៨៨ កថាខណ្ឌ ៧៧, រឿងក្តី Telfner ទល់នឹងប្រទេសអូទ្រីស (សំណើលេខ ៣៣៥០១/៩៦) សាលដីកា ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ (ចូលជាស្ថាពរ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០១) កថាខណ្ឌ ១៥។ សូមមើលផងដែរ កថាខណ្ឌ ៣០ អំពីសេចក្តីអត្ថាធិប្បាយទូទៅលេខ ៣២ របស់គណៈកម្មាធិការសិទ្ធិមនុស្ស ដែលសហព្រះរាជអាជ្ញាលើកយកបង្ហាញនៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៣៥ នៃចម្លើយតបរបស់ខ្លួន។

ដំបូងមានកំហុសអង្គហេតុនេះ បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចឱ្យរួចខ្លួន ត្រូវបង្ហាញថាគ្មានវិមតិសង្ស័យចំពោះការសម្រេចដាក់ពិរុទ្ធភាពទៅលើជនជាប់ចោទ”[54]។

៣៨. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានប្រកាសកាលពីថ្មីៗកន្លងទៅនេះថា៖

> “ជនជាប់ចោទពុំចាំបាច់បង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់នោះទេ គឺគ្រាន់តែរកឱ្យឃើញប្រភពនៃវិមតិសង្ស័យ ពាក់ព័ន្ធនឹងភាពច្បាស់លាស់នៃការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបានហើយ ដើម្បីទាមទារឱ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍ធ្វើការពិនិត្យដោយឯករាជ្យនូវវិចារណកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ផ្អែកលើភ័ស្តុតាងដែលខ្លួនមាន។ (...) នៅក្នុងគ្រប់រឿងក្តីនៅចំពោះមុខតុលាការ កាតព្វកិច្ចក្នុងការពន្យល់អំពីកំហុសដែលលើកឡើងក្នុងសេចក្តីសម្រេចលើពិរុទ្ធភាពមិននាំឱ្យច្រានចោលបន្ទុកបង្ហាញភ័ស្តុតាងឡើយ”[55]។

៣៩. ដូច្នេះ យើងមើលឃើញច្បាស់ថា គោលការណ៍ “វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ” ដែលចារឹកក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រួមនឹងសច្ចធារណ៍និរទោសរហូតដល់សាលក្រមចូលជាស្ថាពរ[56] “ដែលជាការបង្ហាញជាក់លាក់អំពីសច្ចធារណ៍និរទោស”[57] ត្រូវអនុវត្ត

---

[54] សាលដីកា ឌុច កថាខណ្ឌ ១៨។ ចំពោះឧទាហរណ៍ថ្មីៗនៃយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃយន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (លើកឡើងដោយសហព្រះរាជអាជ្ញានៅកំណត់សម្គាល់ជើងទំព័រលេខ ១៥ នៃចម្លើយតបរបស់ខ្លួន)៖ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Karadžić សំណុំរឿងលេខ MICT-13-55-A សាលក្រមចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ កថាខណ្ឌ ១៨។

[55] សាលដីកា Bemba កថាខណ្ឌ ៦៦។

[56] មាត្រា ៣៨ វាក្យខណ្ឌទី ៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[57] តុលាការសិទ្ធិមនុស្សអឺរ៉ុប សាលដីកាលើរឿងក្តី Vassilios Stavropoulos ទល់នឹងប្រទេសក្រិក កថាខណ្ឌ ៣៩, រឿងក្តី Tsalkitzis ទល់នឹងប្រទេសក្រិក (លេខ ២) (សំណើលេខ ៧២៦២៤/១០ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧ (ចូលជាស្ថាពរនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨) កថាខណ្ឌ ៦០។ សូមមើលផងដែរ៖ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ **E50/3/1/4** កថាខណ្ឌ ៣១ (“អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់យ៉ាងមុតមាំថា គោលការណ៍នេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលកើតចេញពីគោលការណ៍ការសន្មតទុកជាមុនថាគ្មានទោស”)។

នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី[58]។ អាស្រ័យហេតុនេះ និងជាពិសេសទៅទៀតនោះ សច្ចធារណ៍និរទោសត្រូវអនុវត្ត នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី រួមទាំងដំណាក់កាលបណ្តឹងសាទុក្ខនៅចំពោះមុខ អ.វ.ត.ក និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។

៤០. ដូចគ្នាផងដែរ សិទ្ធិនៅស្ងៀមមិនឆ្លើយតប និងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង "ដែលជាប់ទាក់ទងយ៉ាងជិតស្និទ្ធ" នឹងសច្ចធារណ៍និរទោស ក៏នៅតែបន្តអនុវត្តផងដែរនៅដំណាក់កាលបណ្តឹងសាទុក្ខ[59] បើតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី[60] ដែលបែរជាចេញសេចក្តីសម្រេចមិនយុត្តិធម៌ដែលបំពេញតែចិត្តរដ្ឋអាជ្ញា។

៤១. អាស្រ័យហេតុនេះ គោលជំហររបស់សហព្រះរាជអាជ្ញាមិនអាចគាំទ្របានទេ ទាំងតាមផ្លូវច្បាប់ ទាំងតាមផ្លូវសីលធម៌។

## ៣. <u>បើតាមសហព្រះរាជអាជ្ញា អ.វ.ត.ក មានបេសកកម្មបញ្ជាក់អំពីសច្ចធារណ៍ពិរុទ្ធភាព និងផ្តល់យុត្តិធម៌បង្គ្រប់កិច្ច</u>

---

[58] សូមមើលផងដែរ៖ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Bemba សំណុំរឿងលេខ ICC-01/05-01/08 សេចក្តីសម្រេចលើការចោទប្រកាន់របស់រដ្ឋអាជ្ញាលើ Jean-Pierre Bemba Gombo អនុលោមតាមវាក្យខណ្ឌ ក) និង ខ) នៃមាត្រា ៦១-៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ៣១ ("ជាចុងក្រោយ អង្គជំនុំជម្រះសូមបញ្ជាក់ថា ដើម្បីសម្រេចលើបញ្ហានេះ អង្គជំនុំជម្រះនឹងផ្អែកលើគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ **ដែលជាសមាសភាគនៃសច្ចធារណ៍និរទោស និងជាគោលការណ៍ទូទៅនៃនីតិវិធីព្រហ្មទណ្ឌ ដែលអនុវត្តនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី** រួមទាំងដំណាក់កាលមុនការជំនុំជម្រះផងដែរ")។

[59] សូមមើលខាងលើ កថាខណ្ឌ ១៥ និងកំណត់សម្គាល់ជើងទំព័រលេខ ១៧ និង ១៨។

[60] រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Karadžić សំណុំរឿងលេខ IT-95-5/18-AR73.11 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទសុំកោះហៅ Zdravko Tolimir ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ ៥០៖ "ជនជាប់ចោទ **ឬម្ចាស់បណ្តឹងឧទ្ធរណ៍** មិនអាចត្រូវបានបង្ខិតបង្ខំ ក្នុងរឿងក្តីរបស់ខ្លួនបានទេ ទោះជាតាមការស្នើសុំរបស់សហជនជាប់ចោទ ឬរដ្ឋអាជ្ញាក្តី ពីព្រោះទង្វើនេះរំលោភលើសិទ្ធិរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ២១(៤)(ឆ)" (មាត្រានេះចែងថា "ជនដែលរងការចោទប្រកាន់ ស្របតាមលក្ខន្តិកៈនេះ មានសិទ្ធិទទួលបានការធានាយ៉ាងស្មើភាពដូចតទៅ៖ [...] ឆ) សិទ្ធិមិនត្រូវបានបង្ខំឱ្យធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬសារភាពថាខ្លួនមានទោស")។

៤២. សហព្រះរាជអាជ្ញាស្នើសុំដោយឥតអៀនខ្មាសឲ្យចៅក្រមជាន់ឈ្លីច្បាប់កម្ពុជា ដែលគោរពសិទ្ធិមនុស្ស សម្រាប់ជាប្រយោជន៍ដល់ប្រជាជនកម្ពុជា និងសិទ្ធិរបស់ជនរងគ្រោះ "ក្នុងការទទួលបានយុត្តិធម៌"[61]។ មេធាវីការពារក្តីស្នើរតែហាមាត់មិនរួច។ សំណាងល្អ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានចេញមុខនិយាយ (តាមកាលកំណត់) ហើយខុសពីព្រះរាជអាជ្ញា ពួកគេមានសេចក្តីក្លាហានក្នុងការទទួលស្គាល់ថា សច្ចធារណ៍និរទោសរបស់ជនជាប់ចោទលាតសន្ធឹងដល់ដំណាក់កាលបណ្តឹងសាទុក្ខ[62]។

៤៣. ដូច្នេះ តុលាការត្រូវផ្តល់យុត្តិធម៌ប្រកបដោយភាពត្រឹមត្រូវ ដើម្បីជាប្រយោជន៍ដល់ប្រជាជនកម្ពុជា និងជនរងគ្រោះ[63] ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស គឺមិនមែនយុត្តិធម៌ធុនអន់ ឬធុនថោកនោះទេ។

## III. <u>ភាពប្រត្យក្សនៃផលប៉ះពាល់នៃមរណភាពរបស់ជនជាប់ចោទដែលបានប្តឹងសាទុក្ខប្រឆាំងនឹងការផ្តន្ទាទោសលើខ្លួននៅមុនពេលចេញសាលដីកា៖ ម្ចាស់បណ្តឹងសាទុក្ខបានទទួលមរណភាពជាជនគ្មានទោស ហើយសាលក្រម ដែលត្រូវបានប្តឹងសាទុក្ខ ពុំមានតម្លៃជាសាលក្រមស្ថាពរទេ</u>

៤៤. សច្ចធារណ៍និរទោសបន្តអនុវត្តរហូតដល់សាលក្រមចូលជាស្ថាពរ។ សាលក្រមសាលាដំបូង ដែលត្រូវបានប្តឹងសាទុក្ខ ពុំមានអាជ្ញាអស់ជំនុំជាសាលក្រមស្ថាពរទេ ដរាបណាពុំទាន់មានការសម្រេចលើបណ្តឹងសាទុក្ខ។

---

[61] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០-១២។

[62] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦។

[63] ឧទាហរណ៍ សូមមើលការថ្លែងនៅក្នុងសវនាការរបស់លោកស្រី Marie GUIRAUD អតីតសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ ប្រតិចារិកសវនាការ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/338.1** ទំព័រ ៣២ ម៉ោងប្រហែល ១១ និង ១៣ នាទី៖ "ខ្ញុំគ្រាន់តែចង់និយាយឡើងវិញអំពីអ្វីដែលខ្ញុំបាននិយាយតាំងពីដើមសវនាការមកម្ល៉េះ គឺថាដើម្បីផលប្រយោជន៍ដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី គឺត្រូវឲ្យសិទ្ធិខាងការពារក្តីនោះត្រូវគោរពផងដែរ"។

៤៥. ដូច្នេះ ជនជាប់ចោទ ដែលបានប្តឹងសាទុក្ខប្រឆាំងនឹងផ្តន្ទាទោសលើខ្លួន ហើយបានទទួលមរណភាព នៅមុនពេលចេញសាលដីកា ត្រូវបានសន្មតថាជាជនគ្មានទោស។ សាលក្រមផ្តន្ទាទោសនៅតែជាសាលក្រមតុលាការ ប៉ុន្តែ ពុំមានអាជ្ញាអស់ជំនុំជាសាលក្រមស្ថាពរនោះទេ។ គ្មានអ្វីផ្សេងទៀតទេ។

៤៦. **__អាស្រ័យហេតុនេះ__** មេធាវីការពារក្តីស្នើសុំតុលាការកំពូលមេត្តា៖

- **បដិសេធ**ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា
- **សម្រេច**ថា សច្ចធារណ៍និរទោសនៅតែបន្តអនុវត្ត នៅដំណាក់កាលបណ្តឹងសាទុក្ខ ហើយ សាលក្រមផ្តន្ទាទោស ដែលត្រូវបានប្តឹងសាទុក្ខ ពុំមានអាជ្ញាអស់ជំនុំជាសាលក្រមស្ថាពរទេ ទោះបីជាជនជាប់ចោទនៅរស់ ឬស្លាប់ក៏ដោយ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស | |